**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍នៃឧទ្យានជាតិព្រះមុនីវង្ស«បូកគោ» លើផ្ទៃដីទំហំ ៨,៦០ ហិកតា (ប្រាំបីហិចតា ហុកសិបអា) ស្ថិតក្នុងភូមិសាស្ត្រ ឃុំម៉ាក់ប្រាំង ស្រុកទឹកឈូ ខេត្តកំពត

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣

- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់ជាតំបន់សហគមន៍នៃឧទ្យានជាតិព្រះមុនីវង្ស«បូកគោ» លើផ្ទៃដីទំហំ ៨,៦០ ហិកតា (ប្រាំបីហិកតា ហុកសិបអា) ស្ថិតក្នុងភូមិសាស្ត្រឃុំម៉ាក់ប្រាំង ស្រុកទឹកឈូ ខេត្តកំពត សម្រាប់ផ្តល់ជូនអគ្គិសនីកម្ពុជាធ្វើជាសារមន្ទីរថាមពលកកើតឡើងវិញនិងឧទ្យានជាតិ **សម្តេច ហ៊ុន សែន កំពត** ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា (Datum: WGS 1984 Zone 48N) ដូចខាងក្រោម៖

| និយាមកាគោល | | | | | |
|---|---|---|---|---|---|
| ID | X | Y | ID | X | Y |
| 1 | 405272 | 1179695 | 6 | 404669 | 1179989 |
| 2 | 405162 | 1179759 | 7 | 404774 | 1179838 |
| 3 | 405076 | 1179800 | 8 | 405093 | 1179655 |
| 4 | 404678 | 1180109 | 9 | 405164 | 1179650 |
| 5 | 404633 | 1180080 | | | |

**មាត្រា២ .-**

តំបន់សហគមន៍នៃឧទ្យានជាតិព្រះមុនីវង្ស«បូកគោ» ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំម៉ាក់ប្រាំង ស្រុកទឹកឈូ ខេត្តកំពត ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងដែលបម្រើឱ្យការអភិវឌ្ឍជាសារមន្ទីរថាមពលកកើតឡើងវិញនិងឧទ្យានជាតិ **សម្តេច ហ៊ុន សែន កំពត** ។ រាល់ការចេញប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤ រោច ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

សាយ សំអាល់

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីកំណត់តំបន់សហគមន៍នៃឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» លើផ្ទៃដីទំហំ ៨,៦០ ហិកតា
ស្ថិតក្នុងភូមិសាស្ត្រ ឃុំម៉ាក់ប្រាំង ស្រុកទឹកឈូ ខេត្តកំពត




| Id | X | Y |
|---|---|---|
| 1 | 405272 | 1179695 |
| 2 | 405162 | 1179759 |
| 3 | 405076 | 1179800 |
| 4 | 404678 | 1180109 |
| 5 | 404633 | 1180080 |
| 6 | 404669 | 1179989 |
| 7 | 404774 | 1179838 |
| 8 | 405093 | 1179655 |
| 9 | 405164 | 1179650 |

ផែនទី និងនិយាមការនេះ
ជាឯកសារភ្ជាប់នឹងអនុក្រឹត្យលេខ ៨២ អនក្រ.បក
ថ្ងៃ សុក្រ ៤ រោច ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩